មជ្ឈមណ្ឌលឯកសារកម្ពុជា
គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
សិក្ខាសាលាជាមួយគ្រូបង្រៀន-ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ប្រាសាទព្រះវិហារ ថ្ងៃទី ២៤-២៦ ខែធ្នូ ឆ្នាំ២០១០

# អត្ថបទពិភាក្សាទី៤
# ប្រសិទ្ធិភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*ដោយ បណ្ឌិត ជា ផល្លា*

ដូចដែលបានបង្ហាញនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ដែលបានបោះពុម្ពនៅឆ្នាំ២០០៩ គោលបំណងនៃការបង្រៀន«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» គឺដើម្បីជំរុញឲ្យមានការព្យាបាលរបួសផ្លូវចិត្ត យុត្តិធម៌ ការផ្សះផ្សា និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ គោលបំណងសម្រាប់គ្រូបង្រៀន គឺដើម្បី«ជំរុញការចង់ដឹងចង់ឮផ្នែកបញ្ញាញាណរបស់សិស្ស ដើម្បីលើកទឹកចិត្តឲ្យមានការត្រិះរិះពិចារណានិងការរីកចំរើនផ្ទាល់ខ្លួន» ។ ដូច្នេះ គ្រូបង្រៀនត្រូវតែពិចារណាទៅលើមេរៀន និងវិធីសាស្ត្រនៃការបង្រៀន ដែលនឹងអភិវឌ្ឍនូវជំនាញនៃការត្រិះរិះពិចារណា និងជំរុញឲ្យសិស្សធ្វើការសិក្សាយ៉ាងសកម្ម ។

## ការពិចារណាអំពីកម្មវិធីសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

គរុកោសល្យក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឬប្រវត្តិសាស្ត្រដទៃទៀត) គួរសង្កត់ធ្ងន់ទៅលើរបៀបបង្រៀនប្រវត្តិសាស្ត្រ របៀបក្នុងការបង្កើតឲ្យមានការរៀបរាប់និងការជជែកដេញដោលអំពីប្រវត្តិសាស្ត្រ និងអំពីរបៀបក្នុងការបង្រៀនសិស្សឲ្យបានច្បាស់លាស់និងមានលក្ខណៈជាប្រព័ន្ធ ។ គ្រូមុខវិទ្យាប្រវត្តិវិទ្យាត្រូវតែធ្វើការទាក់ទងទៅនឹងទស្សនវិស័យ និងវិធីសាស្ត្រស្រាវជ្រាវផ្សេងៗគ្នា ។ គ្រូក៏គួរតែពិភាក្សាអំពីការគិតនៅពីក្រោយមេរៀន គោលបំណង និងវិធីសាស្ត្រដែលជំរុញប្រសិទ្ធភាពនៃការបង្រៀន ។

## ការអភិវឌ្ឍន៍ជំនាញក្នុងការត្រិះរិះពិចារណា

ការបង្រៀនជំនាញក្នុងការត្រិះរិះពិចារណា មានសារសំខាន់ណាស់នៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ ។ សិស្សត្រូវចេះងឿងឆ្ងល់និងមានគំនិតបើកទូលាយ ។ សិស្សត្រូវចេះសួរសំណួរ កំណត់បញ្ហា ស្វែងរកនិងវិភាគការសន្មតឬភាពលំអៀងណាមួយ ពិនិត្យមើលទៅលើភស្តុតាង និងអាចពិនិត្យមើលទៅលើគំនិតផ្សេងៗគ្នា ដើម្បីធ្វើការវាយតម្លៃនិងសម្រេចចិត្តត្រឹមត្រូវ ទៅលើបញ្ហាប្រវត្តិសាស្ត្រ សង្គម បញ្ហាផ្ទាល់

ខ្លួន និងបញ្ហាមនុស្សទូទៅ ។ ប្រសិនបើសិស្សអាចគិតប្រកបដោយការត្រិះរិះពិចារណាបាន សិស្សនឹងមានសមត្ថភាពក្នុងការដំណើរការព័ត៌មាន ដោះស្រាយបញ្ហា និងធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវនៅក្នុងជីវិត ។

## ការជំរុញឲ្យមានការសិក្សាសកម្ម

ការសិក្សាសកម្មគឺជាដំណើរការមួយ ដែលសិស្សធ្វើការទាក់ទងទៅនឹងការគិតកម្រិតខ្ពស់ ដូចជាការវិភាគ ការវាយតម្លៃ និងការបង្កើតថ្មី ។ ការសិក្សាជាក្រុម ការស្រាវជ្រាវ ការធ្វើបទបង្ហាញ និងការ ធ្វើសម្ភាសន៍ និងការសម្តែងតួប្រកបដោយការសហការ គឺជាវិធីសាស្ត្រមួយចំនួន ដែលជំរុញឲ្យមានការសិក្សាសកម្ម និង ជំនាញក្នុងការពិចារណាកម្រិតខ្ពស់ ។

គ្រូត្រូវតែប្តូរថ្នាក់រៀន ដែលអនុវត្តវិធីសាស្ត្រចាស់គ្រូមជ្ឈមណ្ឌល(វិធីសាស្ត្រធ្វើបទបង្កថា) ទៅថ្នាក់រៀនដែលអនុវត្តវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល(វិធីសាស្ត្ររៀនសកម្ម) ដែលគ្រូផ្តល់ឱកាសឲ្យសិស្សមានការឆ្លើយតបច្រើនជាងមុនចំពោះការសិក្សារបស់ខ្លួន ។ នៅក្នុងថ្នាក់រៀនមួយបែបនេះ គ្រូ ជំរុញឲ្យសិស្សធ្វើការច្រើន ជាជាងគ្រាន់តែអង្គុយស្តាប់ និងក្លាយជាអ្នកសិក្សាអសកម្ម ។ សិស្សត្រូវបាន តម្រូវឲ្យអាន ពិភាក្សា សួរសំណួរ ស្រាវជ្រាវ ចូលរួមក្នុងការរៀនមេរៀនថ្មី និងដោះស្រាយបញ្ហា ។

នៅក្នុងឆ្នាំ១៩៥៦ លោក ប៊ែនចាមីន ប្លូម (Benjamin Bloom) បានដឹកនាំអ្នកចិត្តវិទ្យាផ្នែកការអប់រំមួយក្រុម នៅក្នុងការអភិវឌ្ឍន៍ការបែងចែកកម្រិតនៃបញ្ញា ដែលមានសារសំខាន់ក្នុងការសិក្សា ។ លោក ប្លូម បានរកឃើញថា គ្រូភាគច្រើនតម្រូវឲ្យសិស្សគិតតែក្នុងកម្រិតទាបបំផុត គឺគ្រាន់តែរំឭកព័ត៌មានឡើងវិញ ។ នៅក្នុងកម្រិតនេះ សិស្សគ្រាន់តែស្តាប់ ចងចាំ និងសូត្រការពិតពីមេរៀន ដែលមិនតម្រូវឲ្យសិស្សគិត មានការងឿងឆ្ងល់ ស្រមៃ សួរសំណួរ ឬដោះស្រាយបញ្ហានោះទេ ។

លោក ប្លូម បានរកឃើញកម្រិតនៃការគិតចំនួន៦ ដែលមានចាប់តាំងពីការរំឭកឬការរកឃើញការពិតនៃមេរៀនធម្មតា(ដែលជាកម្រិតទាបបំផុត) ទៅការអនុវត្តន៍ ការវិភាគ និងការវាយតម្លៃ(ដែលជាកម្រិតនៃការគិតប្រកបដោយភាពស្មុគស្មាញនិងអរូបិយ) រហូតដល់ការបង្កើតថ្មី(ដែលជាកម្រិតខ្ពស់បំផុត) ។ កិរិយាស័ព្ទសកម្មដែលតំណាងឲ្យសកម្មភាពនៃបញ្ញាញាណ ទៅលើកម្រិតនីមួយៗ ត្រូវបានរៀបរាប់នៅក្នុងតារាងកម្រិតនៃការគិតរបស់លោក ប្លូម (Bloom Taxonomy Chart) ។

**តារាងកម្រិតនៃការគិត (Bloom Taxonomy Chart)**

| | | |
|---|---|---|
| **ការបង្កើត** ៖ តើសិស្សអាចបង្កើតផលិតផលឬគំនិតថ្មីបានដែរឬទេ? | បង្កើតគំនិតថ្មី ផលិតផលថ្មី ឬការមើលឃើញទៅលើអ្វីផ្សេងៗដែលថ្មី | ការគូរប្លង់ ការសាងសង់ ការធ្វើផែនការ ការផលិត ការឆ្នៃប្រឌិត ការបង្កើត ការអភិវឌ្ឍន៍ |
| **ការវាយតម្លៃ** ៖ តើសិស្សអាច | បង្ហាញពីភាពត្រឹមត្រូវ នៃការធ្វើ | ត្រួតពិនិត្យមើល ការធ្វើសម្មតិកម្ម |

| | | |
|---|---|---|
| បង្ហាញពីភាពត្រឹមត្រូវ នៃដំណើរការ សម្រេចចិត្តមួយបានដែរឬទេ? | សេចក្តីសម្រេចចិត្តមួយ ឬសកម្មភាពមួយ | ការរិះគន់ ការពិសោធន៍ ការកាត់សេចក្តី ការវាយតម្លៃ ការគាំទ្រ |
| **ការវិភាគ** ៖ តើសិស្សអាចធ្វើការបែងចែក រវាងផ្នែកផ្សេងៗបានដែរឬទេ? | បែងចែកព័ត៌មានទៅជាផ្នែកៗ ដើម្បីពិនិត្យមើលទៅលើការស្វែងយល់ និងទំនាក់ទំនង | ការប្រៀបធៀប ការរកចំណុចខុសគ្នា ការចាត់ចែង ការពិសោធន៍ ការបំបែកជាផ្នែកៗ ការពិនិត្យមើលការសួរនាំ និងការរកឃើញ |
| **ការអនុវត្តន៍** ៖ តើសិស្សអាចប្រើប្រាស់ព័ត៌មាន នៅក្នុងរបៀបមួយថ្មីផ្សេងទៀតដែរឬទេ? | ប្រើប្រាស់ព័ត៌មាននៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នាមួយផ្សេងទៀត | ការប្រតិបត្តិ ការធ្វើការ ការប្រើប្រាស់ ការអនុវត្តន៍ការងារ ការដោះស្រាយ ការធ្វើដំណើរការ ការបង្ហាញ ការបកស្រាយ ការសរសេរ |
| **ការយល់** ៖ តើសិស្សអាចពន្យល់គំនិតឬទស្សនៈអ្វីមួយបានដែរឬទេ? | ពន្យល់អំពីគំនិត ឬទស្សនៈ | ការបកស្រាយ ការពណ៌នា ការសង្ខេប ការពិភាក្សា ការសង្ខេបប្រយោគ ការបែងចែក ការពន្យល់ ការកំណត់អត្តសញ្ញាណ និងការកំណត់ទីកន្លែង |
| **ការចងចាំ** ៖ តើសិស្សអាចនឹកឃើញ ឬចងចាំព័ត៌មានដែរឬទេ? | ការរំឭកព័ត៌មាន | ការស្គាល់ ការរៀបបញ្ជី ការនឹកឃើញឡើងវិញ ការដាក់ឈ្មោះ ការរំឭកមេរៀន ការថាតាម ការចម្លងតាម ការកំណត់និយមន័យ |

តាមរយៈគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រូត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ដើម្បីបង្រៀនសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងដើម្បីបណ្តុះចំណេះដឹងរបស់សិស្ស និងជំនាញក្នុងការត្រិះរិះពិចារណា នៅក្នុងបរិយាកាសថ្នាក់រៀនសមរម្យមួយ ។ វិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយ សម្រាប់បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺវិធីសាស្ត្រប្រើសំណួរបែប សូក្រាត ។ ការសិក្សាបែប សូក្រាត ជំរុញឲ្យសិស្សធ្វើការត្រិះរិះពិចារណា វាយតម្លៃ និងអនុវត្តចំណេះដឹង ។ វិធីសាស្ត្រនេះគួរតែប្រើឲ្យបានច្រើនតាមតែអាចធ្វើទៅបាន នៅក្នុងការពិភាក្សានៅក្នុងថ្នាក់រៀន និងការដាក់កិច្ចការធ្វើនៅផ្ទះ ។ គ្រូបង្រៀនគួរតែ ៖

- ទុកពេលឲ្យសិស្សពិចារណាសំណួរនិងការឆ្លើយតប មុនពេលសុំចម្លើយពីសិស្ស ។

- ជៀសវាងសំណួរដែលមានចម្លើយ“ត្រូវឬខុស” ដែលមិនជំរុញដល់ការគិតឬការពិភាក្សា ។
- ត្រូវដឹងថា សិស្សត្រូវការព័ត៌មានបឋមនិងធនធានឯកសារផ្សេងៗទៀត ដើម្បីឆ្លើយទៅនឹងសំណួរដែលគ្រូដាក់ឲ្យ ។
- សួរសំណួរទម្រង់បើក ដើម្បីជំរុញឲ្យមានការត្រិះរិះពិចារណា ។
- ប្រើប្រាស់សំណួរឬការពន្យល់បញ្ជាក់ ដើម្បីណែនាំសិស្ស ខណៈពេលដែលសិស្សកំពុងតែស្វែងរកចម្លើយដែលត្រឹមត្រូវ ។
- ប្រើប្រាស់សំណួរគ្រប់កម្រិតនៃការគិតទាំងអស់ ដើម្បីអភិវឌ្ឍន៍ការត្រិះរិះពិចារណាខ្ពស់ជាងមុន ក៏ដូចជាអភិវឌ្ឍចំណេះដឹងទូទៅ និងកម្រិតនៃការយល់ដឹងរបស់សិស្ស ។

ខាងក្រោមគឺជាវិធីសាស្រ្តបន្ថែមទៀត ដើម្បីជួយអភិវឌ្ឍជំនាញក្នុងការត្រិះរិះពិចារណា និងជំរុញដល់ការសិក្សាសកម្ម ។

## វិធីសាស្រ្តណែនាំ

| វិធីសាស្រ្ត | ការពិពណ៌នា |
|---|---|
| **K-W-L** | វិធីសាស្រ្តនេះត្រូវបានប្រើ ដើម្បីស្វែងយល់ពីអ្វីដែលសិស្សបានដឹងមុនពេលរៀនមេរៀន អ្វីដែលសិស្សចង់ដឹងក្នុងកំឡុងពេលនៃការរៀនមេរៀន និងនៅទីបញ្ចប់អ្វីដែលសិស្សបានរៀន បន្ទាប់ពីបញ្ចប់មេរៀន ។ K-W-L អាចត្រូវបានប្រើប្រាស់ដើម្បីផ្សារភ្ជាប់សិស្សទៅនឹងប្រធានបទថ្មី រំឭកចំណេះដឹងដែលមានពីមុន ចែករំលែកគោលបំណងនៃមេរៀន និងគ្រប់គ្រងការរៀន ។ |
| **ការស្រង់គំនិត Brainstorming** | គឺជារបៀបរៀនមួយ ដែលអ្នកសិក្សាមួយក្រុមចូលរួមចំណែកគំនិតជាបន្តបន្ទាប់ ។ |
| **សកម្មភាពធ្វើការជាដៃគូ (Think-Pair Share)** | សិស្សគិតជាបុគ្គល បន្ទាប់មកធ្វើការជាដៃគូ(ដោយពិភាក្សាជាមួយដៃគូរបស់ខ្លួន) បន្ទាប់មកទៀត សិស្សចែករំលែកគំនិតនៅក្នុងថ្នាក់រៀនទាំងមូល ។ វិធីសាស្រ្តពិភាក្សានេះផ្តល់ឱកាសឲ្យសិស្ស ឆ្លើយតបទៅនឹងសំណួរជាសំណេរ ប្រកបដោយការពិចារណា និងឲ្យសិស្សចូលរួមក្នុងការពិភាក្សាប្រកបដោយអត្ថន័យ ជុំវិញប្រធានបទណាមួយ ជាមួយសិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។ |
| **វិនដ្យាក្រាម (Venn Diagram)** | គឺជាក្រាហ្វិកមួយ ដែលត្រូវបានប្រើប្រាស់ ដើម្បីជួយសិស្សក្នុងការរៀបចំព័ត៌មានដោយធ្វើការប្រៀបធៀប និងរកចំណុចខុសគ្នា ។ |
| **ការណែនាំពិភាក្សា** | ការពិភាក្សាក្នុងថ្នាក់រៀនជាទូទៅចាប់ផ្តើមដោយគ្រូរៀបរាប់ពីគោលដៅឬគោល |

| | |
|---|---|
| **(Guided Discussions)** | *បំណាន់នៃការពិភាក្សា ដូនកាលការពិភាក្សាអាចត្រូវបានផ្តួចផ្តើមដោយចោទសំណួរទម្រង់បើកដើម្បីជួយឲ្យសិស្សធ្វើការបកស្រាយ ។* |
| ***សំណួរណែនាំ*** **(Guided Questioning)** | *គឺជាវិធីសាស្ត្រមួយ ដែលសំណួរទាំងឡាយរបស់គ្រូ ឲ្យគំរុយជាច្រើនអំពីអ្វីដែលនឹងកើតឡើងនៅក្នុងការអាន ។ បន្ទាប់មក នៅពេលដែលការយល់ដឹងមានការកើនឡើង ការប្រើប្រាស់សំណួរដើម្បីគាំទ្រការយល់ដឹង មានការថយចុះ ។* |
| ***ការណែនាំអាន*** **(Guided Reading)** | *គឺជាវិធីនៃការអានមួយ ដែលសិស្សអានអត្ថបទខ្លីៗ បន្ទាប់មក ការបកស្រាយទាំងឡាយរបស់សិស្ស ត្រូវបានកត់ត្រា ពិភាក្សា និងកែសម្រួល ។* |
| ***ការសង្ខេប*** **(Summarizing)** | *សិស្សធ្វើការសម្រេច ថាអ្វីដែលមានសារសំខាន់ជាងគេនៅក្នុងអត្ថបទ ហើយធ្វើការសង្ខេបដោយប្រើប្រាស់ភាសារបស់ខ្លួន ។* |
| ***ការមើលឃើញនឹងភ្នែក*** **(Visuals)** | *គឺជាសម្ភារៈសម្រាប់បង្ហាញជាច្រើន ដូចជាការបញ្ចាំងស្លាយ ភាពយន្ត គំរូម៉ូដែល រូបភាព ផែនទី បណ្ណព័ត៌មាន និងសៀវភៅ ដែលត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ និងអភិវឌ្ឍន៍ការយល់ដឹង ការសិក្សា ឬការកោតសរសើរ ។* |
| ***ការសម្តែងតួ*** **(Role Playing)** | *គឺការដើរតួ (អាចជាការដើរតួអ្វីមួយ ដែលអ្នកមិនដែលធ្វើ) ដែលជាផ្នែកមួយនៃការសិក្សា ដែលនាំដល់ការយល់ដឹងអំពីតួនាទីមួយ ឬស្ថានភាពមួយ ។ ការរៀបចំផែនការ និងការដើរតួនៅក្នុងថ្នាក់រៀន អាចធ្វើឲ្យជំនាញក្នុងការអាននិងការសម្តែងតួកាន់តែប្រសើរឡើង និងជួយលើកទឹកចិត្តដល់សិស្ស ដែលទទួលបានប្រយោជន៍ពីការប្រាស្រ័យទាក់ទងក្នុងសង្គម និងចំណុចផ្សេងៗទៀតពីការសម្តែងតួ ។* |
| ***ប្រអប់សង្គ្រោះជីវិត*** **(Survival Box)** | *វិធីសាស្ត្រនេះសាកល្បងជំនាញនៃការគិតកម្រិតខ្ពស់ និងជំនាញក្នុងការដោះស្រាយបញ្ហា ។ វិធីសាស្ត្រនេះអនុញ្ញាតឲ្យសិស្សចេះដោះស្រាយបញ្ហា និងប្រើប្រាស់ជំនាញក្នុងការសង្គ្រោះជីវិត ។* |
| ***ការគ្រោងប្លង់*** **(Mapping)** | *ការគ្រោងប្លង់ព័ត៌មាន ជួយសិស្សក្នុងការវិភាគ រៀបចំ និងបង្ហាញព័ត៌មានប្រកបដោយប្រសិទ្ធភាព ។* |
| ***កាលបរិច្ឆេទ*** **(Timeline)** | *វិធីសាស្ត្រនេះជួយសិស្សឲ្យយល់និងចងចាំ ព្រឹត្តិការណ៍តាមកាលវេលា ។* |
| ***កំណត់ហេតុ និងទិនានុប្បវត្តិ*** **(Diary and Journal Writing)** | *ប្រភេទនៃសំណេរបែបនេះ ត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីជំរុញឲ្យមានការឆ្លុះបញ្ចាំងឬស្វែងរកចំណុចនៃគំនិតដែលសិស្សចាប់អារម្មណ៍ ។* |
| ***ការសរសេរកំណាព្យ*** | *ការតែងកំណាព្យជំរុញ លើកទឹកចិត្តឲ្យសិស្ស ក្នុងការបង្ហាញគំនិត ប្រកបដោយការ* |

| | |
|---|---|
| **(Poetry Writing)** | ស្រមៃនិងទំនាក់ទំនងខ្ពស់ ។ |
| **សម្ភាសន៍ (Interview)** | វិធីមួយដើម្បីឲ្យសិស្សចេះប្រមូលព័ត៌មាន គឺការធ្វើសម្ភាសន៍ ។ ដំណើរការនៃការធ្វើសម្ភាសន៍ ផ្តល់ឲ្យសិស្សនូវភាពជាម្ចាស់លើចំណេះដឹងច្រើនជាងមុន ជាពិសេសនៅពេលសិស្សបង្កើតសំណួរសម្រាប់សម្ភាសន៍ និងទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានទាំងនោះ ទៅសិស្សផ្សេងទៀតនៅក្នុងថ្នាក់ ។ |
| **វាគ្មិន (Guest Speaker)** | វាគ្មិនចូលមកក្នុងថ្នាក់ ដើម្បីចែករំលែកចំណេះដឹងជំនាញ និងបទពិសោធន៍ ។ វាគ្មិនជួយសិស្ស ក្នុងការតភ្ជាប់ចំណេះដឹងដែលតម្រូវឲ្យរៀននៅក្នុងថ្នាក់រៀន និងការអនុវត្តន៍ក្រៅថ្នាក់រៀន ។ |
| **ក្រុមសហការ (Cooperative Group)** | សិស្សបែងចែកទៅជាក្រុមតូចៗ ដើម្បីដោះស្រាយបញ្ហា សហការ ចែករំលែកនិងប្រគល់ការទទួលខុសត្រូវ អនុវត្តនិងធ្វើទំនាក់ទំនងជាមួយអ្នកផ្សេងទៀត ដែលមានសមត្ថភាពផ្សេងៗគ្នា ។ ការទទួលខុសត្រូវរបស់ក្រុមនីមួយៗរួមមាន ៖ អ្នកសម្របសម្រួលឬប្រធានក្រុម អ្នកកត់ត្រា អ្នករក្សាពេលវេលា និងអ្នកជំរុញលើកទឹកចិត្ត ។ |
| **បទបង្ហាញ (Presentation)** | សិស្សពន្យល់ ឬបង្ហាញចំណេះដឹងដែលខ្លួនបានរៀនទៅអ្នកស្តាប់ ។ |
| **ភាពយន្ត (Films)** | រូបភាពដែលមានចលនា អាចត្រូវបានប្រើប្រាស់ដើម្បីជំរុញការសិក្សាផ្នែកអក្សរសាស្ត្រ ភាសា និងប្រវត្តិវិទ្យា ។ |
| **ប័ណ្ណព័ត៌មាន (Brochure)** | សកម្មភាពនេះផ្តល់ឱកាសឲ្យសិស្ស ក្នុងការផ្តោតការយកចិត្តទុកដាក់ទៅលើគោលបំណងមួយនិងទស្សនិកជនមួយរូប ។ សិស្សត្រូវប្រកាន់យកជំហរមួយ កំណត់នូវព័ត៌មានអ្វីខ្លះដែលខ្លួនចង់ឬមិនចង់ចែករំលែក និងដំណើរការផ្សេងៗទៀតដែលខ្លួនចង់តាមដាន ដើម្បីបញ្ចប់កិច្ចការ ។ ប័ណ្ណព័ត៌មានរួមបញ្ចូលធាតុផ្សំដែលអាចមើលឃើញ ជាផ្នែកមួយនៃការទំនាក់ទំនងប្រកបដោយព័ត៌មានគ្រប់គ្រាន់ ។ |
| **តែងសេចក្តី (Essay)** | គឺជាសំណេរខ្លីមួយ ដែលពិភាក្សាជុំវិញប្រធានបទមួយ ។ |
| **ការស្រាវជ្រាវ (Research)** | គឺជាសកម្មភាពមួយ ដែលអ្នកសិក្សាធ្វើការស៊ើបអង្កេត ឬប្រមូលព័ត៌មានអំពីប្រធានបទជាក់លាក់ណាមួយ ។ |
| **ការសិក្សាប្រៀបធៀប (Comparative Study)** | គឺជាវិធីសាស្ត្រស្រាវជ្រាវមួយ ដែលធ្វើការប្រៀបធៀបប្រធានបទជាច្រើន ដូចជាប្រទេសឬវប្បធម៌ ។ ជាទូទៅ ការសិក្សាប្រៀបធៀបគឺជាសកម្មភាពនៃការប្រៀបធៀបរបស់ពីរឬច្រើន ដើម្បីស្វែងរកអ្វីមួយ ចេញពីរបស់មួយឬរបស់ទាំងអស់នោះ |

| | |
|---|---|
| | ដែលយើងកំពុងតែប្រៀបធៀប ។ |
| **ការពិនិត្យមើលឡើងវិញ (Review)** | គឺជាការពិនិត្យមើលឡើងវិញ នូវការសិក្សាក្នុងកំឡុងពេលនៃវគ្គសិក្សាមួយ ។ |
| **ជីកសរ (Jigsaw)** | គឺជាការបំបែកប្រធានបទសិក្សា ដែលសិស្សត្រូវស្រាវជ្រាវនិងរៀននៅក្នុងក្រុម បន្ទាប់មក ដាក់ប្រធានបទទាំងអស់នោះចូលគ្នាវិញ នៅក្នុងទម្រង់មួយដែលសិស្សបង្រៀនគ្នាទៅវិញទៅមក រវាងក្រុមនិងក្រុម ។ |
| **ការសរសេរសំបុត្រ (Letter Writing)** | គឺជាសកម្មភាពសរសេរមួយ ដែលលើកទឹកចិត្តដល់សិស្ស ឲ្យគិតអំពីទស្សនិកជនណាម្នាក់ ។ |
| **ដំណើរទស្សនកិច្ចសិក្សា (Field Trip)** | គឺជាសកម្មភាពមួយ ដែលកើតឡើងនៅខាងក្រៅថ្នាក់រៀន ក្នុងគោលបំណងដើម្បីពង្រីកការសិក្សារបស់សិស្ស និងផ្តល់បទពិសោធន៍ជាក់ស្តែង ជាមួយនឹងឧបករណ៍ ឬមនុស្ស ។ |
| **ការវាយតម្លៃ (Assessment)** | គឺជាការវាយតម្លៃមួយ ដែលត្រូវបានរៀបចំឡើង ដើម្បីធ្វើការវាស់ស្ទង់ការយល់ដឹងរបស់សិស្សទៅលើមេរៀន ឬសមត្ថភាពរបស់សិស្សក្នុងការអនុវត្តន៍ជំនាញ ។ |

ការប្រើប្រាស់ការសិក្សាសកម្មនៅក្នុងថ្នាក់រៀន គឺមានសារសំខាន់ណាស់ ដោយសារតែការសិក្សារបៀបនេះមានឥទ្ធិពលខ្លាំងក្លា មកលើការសិក្សារបស់សិស្ស ។ ដូច្នេះ ពីវិធីសាស្រ្តប្រកបដោយការត្រិះរិះពិចារណា រហូតដល់ការបង្រៀនប្រកបដោយជំនាញនិងប្រសិទ្ធភាព តម្រូវឲ្យគ្រូមានចំណេះដឹងគ្រប់គ្រាន់ទៅលើវិធីសាស្រ្ត ដែលមានរាយនៅក្នុងតារាងខាងលើ និងនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ដើម្បីអភិវឌ្ឍជំនាញក្នុងការត្រិះរិះពិចារណា និងការសិក្សាសកម្ម ។ ជាងនេះទៅទៀត គ្រូម្នាក់ៗគួរតែធ្វើការឆ្លុះបញ្ចាំងមកលើខ្លួនឯង ដើម្បីពិនិត្យមើលការតាំងចិត្តផ្ទាល់ខ្លួន ដើម្បីអនុវត្តវិធីសាស្រ្តក្នុងការបង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ ។

## ការសិក្សារបស់សិស្ស

ការស្រាវជ្រាវជាច្រើនអំពីរបៀបនៃការសិក្សារបស់មនុស្ស ត្រូវបានសរសេរឡើងនៅក្នុងកំឡុងពេលពីរទសវត្សរ៍ចុងក្រោយនេះ ។ ការបោះពុម្ពផ្សាយរបស់ក្រុមប្រឹក្សាស្រាវជ្រាវជាតិក្នុងឆ្នាំ២០០០ ដែលមានចំណងជើងថា <u>របៀបនៃការសិក្សារបស់មនុស្ស : ខួរក្បាល គំនិត បទពិសោធន៍ និងសាលារៀន</u> បានបង្ហាញអំពីចំណុចដូចខាងក្រោម :

១. ការស្រាវជ្រាវបានបង្ហាញយ៉ាងច្បាស់ថា មនុស្សម្នាក់ត្រូវតែមានការចូលរួមដើម្បីរៀន ។ មនុស្សរៀនដោយការចូលរួមយ៉ាងសកម្ម នៅក្នុងការសង្កេតមើល និយាយ សរសេរ ស្តាប់ គិត គូស និងធ្វើ ។

២. ការសិក្សានិងកាន់តែរីកធំឡើងទៀត នៅពេលមនុស្សមើលឃើញសក្តានុពលនៃការជាប់ពាក់ព័ន្ធ ការអនុវត្តន៍ និងផលប្រយោជន៍ទៅកាន់អ្នកផ្សេងទៀត ។

៣. ការសិក្សាអភិវឌ្ឍចេញពីការយល់ដឹងនាពេលបច្ចុប្បន្ន ។

## ការបង្រៀនប្រកបដោយប្រសិទ្ធភាព

យោងតាមការបោះពុម្ពផ្សាយរបស់ក្រុមប្រឹក្សាស្រាវជ្រាវជាតិ ឆ្នាំ២០០០ ស្តីអំពី *របៀបនៃការសិក្សារបស់មនុស្ស ៖ ខួរក្បាល គំនិត បទពិសោធន៍ និងសាលារៀន* ការសិក្សាប្រកបដោយប្រសិទ្ធភាពមានន័យថាការធ្វើឲ្យសិស្សចូលរួមយ៉ាងសកម្ម ។ ដូច្នេះ គ្រូត្រូវបង្ហាញវត្ថុបំណងនៃមេរៀនឲ្យបានច្បាស់ លាស់ បង្រៀនឲ្យចំគោលដៅនៃវត្ថុបំណងទាំងនោះ ធ្វើឲ្យការសិក្សាមានភាពច្បាស់លាស់ ប្រកបដោយអត្ថន័យឲ្យបានច្រើនតាមតែអាចធ្វើទៅបាន និងផ្តល់ការអនុវត្តន៍ដែលទាក់ទងនឹងមេរៀន និងសកម្មភាពអនុវត្តន៍ដោយឯករាជ្យ ដែលផ្តោតទៅលើចំណុចខាងក្រោម ៖

| | |
|---|---|
| **ចំណាប់អារម្មណ៍ និង ការពន្យល់** | ការបង្រៀនល្អ គឺជាការបន្តឲ្យមានការចាប់អារម្មណ៍ទៅលើការសិក្សា ។ វាជួយឲ្យសិស្សមានអារម្មណ៍ថា ខ្លួនអាចជាកម្មសិទ្ធិលើការសិក្សា ហើយប្រើប្រាស់ចំណេះដឹងដើម្បីស្វែងរកអត្ថន័យនៃពិភពលោក ដែលនៅជុំវិញខ្លួន ។ គួបផ្សំជាមួយនឹងតម្រូវការក្នុងការបង្កើតមេរៀនដែលជាប់ទាក់ទង គ្រូត្រូវបង្កើតការពន្យល់ ដែលអាចធ្វើឲ្យសិស្សយល់ពីសម្ភារៈ ។ គ្រូត្រូវដឹងថា អ្វីដែលសិស្សយល់ ហើយបន្ទាប់មកត្រូវផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្វីដែលសិស្សបានដឹង និងអ្វីដែលថ្មី ។ |
| **ការខ្វល់ខ្វាយនិងការគោរពចំពោះសិស្ស និងការសិក្សារបស់សិស្ស** | ការបង្រៀនល្អទាក់ទងទៅនឹងការធ្វើឲ្យអ្វីៗទាំងឡាយឲ្យ មានភាពងាយស្រួលសម្រាប់សិស្សក្នុងការសិក្សា ។ វាគឺជាការបង្រៀនមួយ ដែលតែងតែព្យាយាមជួយសិស្សឲ្យមានអារម្មណ៍ថា ខ្លួនអាចយល់ច្បាស់ពីមេរៀនមួយបាន ។ វាជួយលើកទឹកចិត្តឲ្យសិស្ស ក្នុងការសាកល្បងសិក្សាអ្វីមួយដោយខ្លួនឯង និងសម្រេចអ្វីមួយបានយ៉ាងឆាប់រហ័ស ។ |
| **ការវាយតម្លៃនិងការផ្តល់យោបល់** | ការបង្រៀនល្អទាក់ទងទៅនឹងការប្រើប្រាស់ វិធីសាស្ត្រវាយតម្លៃផ្សេងៗជាច្រើន និងអនុញ្ញាតឲ្យសិស្ស បង្ហាញអំពីការយល់ដឹងច្បាស់លាស់របស់ខ្លួនទៅលើមេរៀន |

| | |
|---|---|
| **កែរលម្អសមស្របមួយ** | *ក្នុងលក្ខណៈផ្សេងៗគ្នា ។* |
| **គោលដៅច្បាស់លាស់ និងការប្រឈមផ្នែកបញ្ញាញាណ** | *ការបង្រៀនល្អគឺជាការកំណត់នូវបទដ្ឋានកម្រិតខ្ពស់មួយឲ្យសិស្ស ។ សិស្សក៏ត្រូវដឹងគោលដៅនៃការសិក្សាច្បាស់លាស់ផងដែរ ។ សិស្សគួរតែដឹងជាមុន អ្វីដែលខ្លួនត្រូវរៀន និងអ្វីដែលខ្លួនត្រូវធ្វើ ជាមួយនឹងអ្វីដែលខ្លួនបានដឹង ។* |
| **ឯករាជ្យ ការគ្រប់គ្រង និងការចូលរួមយ៉ាងសកម្ម** | *ការបង្រៀនល្អគឺជាការជំរុញ ឲ្យសិស្សមានការគ្រប់គ្រងទៅលើការសិក្សា និងការចាប់អារម្មណ៍ទៅលើប្រធានបទ ។ គ្រូល្អបង្កើតឡើងនូវកិច្ចការរៀនសូត្រ ដែលសមរម្យទៅនឹងកម្រិតយល់ដឹងរបស់សិស្ស ។* |
| **ការសិក្សាពីសិស្ស** | *ការបង្រៀនល្អគឺជាការបើកទូលាយចំពោះការផ្លាស់ប្តូរ ។ វាទាក់ទងទៅនឹងការសាកល្បងជាប្រចាំ ក្នុងការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន ដើម្បីបង្ហាញពីតម្រូវការនៃការសិក្សារបស់សិស្ស ។* |

*គ្រូត្រូវបង្កើតបរិយាកាសមួយ ដែលលើកទឹកចិត្តដល់ការស្រមៃគិតរបស់សិស្ស ដឹកនាំការយល់ដឹងរបស់សិស្ស និងជំរុញដល់លទ្ធផលនៃការសិក្សាប្រកបដោយផ្លែផ្កា ទៅលើប្រធានបទណាមួយ ។ គ្រូក៏ត្រូវបង្កើតទម្លាប់នៅក្នុងថ្នាក់រៀនទៀងទាត់មួយ ហើយត្រូវមានចំណេះដឹងលើប្រធានបទ និងរៀបចំកិច្ចតែងការបង្រៀនឲ្យបានរួចរាល់ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពជារៀងរាល់ថ្ងៃ ។*

*មិនមានវិធីសាស្ត្រត្រឹមត្រូវតែមួយគត់ ក្នុងការចាប់ផ្តើមការបង្រៀននោះទេ ។ ទោះជាយ៉ាងនេះក្តី ការចំណាយពេលបន្តិច ដើម្បីសញ្ជឹងគិតពិចារណាទៅលើប្រធានបទ អានអត្ថបទខ្លីមួយ ឬការគិតពីប្រធានបទណាមួយ នឹងអាចជួយឲ្យគ្រូផ្តោតការយកចិត្តទុកដាក់ទៅលើមេរៀន ។*

*រឿងខ្លីមួយគឺជាវិធីដ៏ល្អមួយ ក្នុងការបង្កើតឲ្យមានការចាប់អារម្មណ៍ ចិត្តអាណិតអាសូរទៅលើមនុស្សមួយក្រុមឬយល់អំពីផលប៉ះពាល់នៃព្រឹត្តិការណ៍ដ៏ស៊ីជម្រៅណាមួយ ។ វាអាចធ្វើឲ្យបណ្តុំនៃការស្រមៃមួយអាចធ្វើដំណើរទៅមុខបាន ។ ការឲ្យសិស្សគូររូបភាពពីទិដ្ឋភាពមួយនៅក្នុងសៀវភៅ ដែលសិស្សទាំងអស់កំពុងអានឬពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រណាមួយ អាចជាវិធីដ៏មានប្រសិទ្ធភាពមួយ ដើម្បីជួយឲ្យសិស្សផ្តោតការយកចិត្តទុកដាក់ទៅលើមេរៀន ។*

*នៅពេលគ្រូអាចទាក់ទាញការចង់ដឹងចង់ឮរបស់សិស្សបាន គ្រូត្រូវដឹកនាំការចាប់អារម្មណ៍នេះទៅកាន់មេរៀន ។ ការផ្សារភ្ជាប់ការចង់ដឹងចង់ឮរបស់សិស្សនៅពេលចាប់ផ្តើមរៀនមេរៀន និងការទាញការចង់ដឹងចង់ឮនោះទៅក្នុងមេរៀន គឺជាជំហានមួយដ៏មានសារសំខាន់ដំបូងបំផុត ក្នុងការបង្រៀនមេរៀនមួយប្រកប*

ដោយប្រសិទ្ធភាពជារៀងរាល់ថ្ងៃ ។ គ្រូគួរតែផ្សារភ្ជាប់ការចង់ដឹងចង់ឮនេះ ទៅលើខ្លឹមសារឬជំនាញ ដែលចាំបាច់ដើម្បីចូលរួមក្នុងការរៀនមេរៀន ។

គោលការណ៍៧យ៉ាងនៃការអនុវត្តន៍ល្អខាងក្រោម គឺជាសេចក្តីណែនាំសម្រាប់គ្រូបង្រៀននិងសិស្សក្នុងការធ្វើឲ្យប្រសើរឡើងនូវការបង្រៀននិងការរៀន នៅក្នុងគ្រប់មុខវិជ្ជាសិក្សាទាំងអស់ មិនមែនតែមុខវិជ្ជាប្រវត្តិសាស្ត្រនោះទេ ។ គោលការណ៍ទាំងនេះអាចប្រើប្រាស់បាន ជាមួយសិស្សជាច្រើនប្រភេទ ដែលមកពីមុខជំនាញផ្សេងៗគ្នាជាច្រើន ដែលរួមទាំងបុរស ស្ត្រី អ្នកមាន អ្នកក្រ ចាស់ ក្មេង អ្នកត្រៀមខ្លួនបានល្អ និងអ្នកមិនបានត្រៀមខ្លួន ។

## គោលការណ៍៧យ៉ាងនៃការអនុវត្តល្អ
**(Seven Principles of Good Practices)**

| | |
|---|---|
| **១. ទំនាក់ទំនង (Contact)** | គ្រូត្រូវជំរុញលើកទឹកចិត្តដល់សិស្ស ឲ្យធ្វើការទាក់ទងជាមួយខ្លួនជាប្រចាំ ដើម្បីជំរុញឲ្យសិស្សមានការចូលរួម ។ |
| **២. ការសហការ (Cooperation)** | គ្រូអភិវឌ្ឍការសហការក្នុងចំណោមសិស្ស ដែលជាវិធីមួយក្នុងការសម្រួចការគិត និងពង្រីងការយល់ដឹងរបស់សិស្ស ។ |
| **៣. ការសិក្សាសកម្ម (Active Learning)** | គ្រូជំរុញឲ្យមានការសិក្សាសកម្ម ដែលជាវិធីមួយដើម្បីឲ្យសិស្សនិយាយ អំពីអ្វីដែលសិស្សកំពុងរៀន សរសេរ ធ្វើទំនាក់ទំនងទៅនឹងបទពិសោធន៍ពីអតីតកាល ហើយយកមកប្រើប្រាស់ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។ |
| **៤. យោបល់កែលម្អ (Feedback)** | គ្រូមានយោបល់កែលម្អសមស្រប ដែលជាវិធីមួយក្នុងការវាយតម្លៃចំណេះដឹង និងសមត្ថភាព ដែលសិស្សមានកន្លងមក និងដើម្បីឲ្យសិស្សដឹងអំពីអ្វីដែលខ្លួនបានរៀន និងអ្វីដែលខ្លួនត្រូវរៀនបន្ថែម ។ |
| **៥. ពេលវេលា លើកិច្ចការ (Time on Task)** | គ្រូសង្កត់ធ្ងន់ទៅលើពេលវេលាលើកិច្ចការ ដែលជាវិធីមួយក្នុងការបែងចែកពេលវេលាជាក់លាក់មួយ និងគ្រប់គ្រងការសិក្សាប្រកបដោយប្រសិទ្ធភាពរបស់សិស្ស ។ |
| **៦. ការរំពឹងទុក (Expectation)** | គ្រូពិភាក្សាការរំពឹងទុកខ្ពស់ ដែលជាវិធីមួយក្នុងការកសាងការអប់រំខ្ពស់មួយសម្រាប់សិស្សទាំងអស់ ។ |
| **៧. របៀបរៀន (Learning Style)** | គ្រូគោរពទេពកោសល្យនិងវិធីរៀនផ្សេងៗគ្នា ដែលជាវិធីមួយក្នុងការបញ្ជាក់ទៅលើទេពកោសល្យនិងរបៀបរៀនផ្សេងៗគ្នា នៅក្នុងថ្នាក់ ។ |

នៅពេលការរំពឹងទុក ការទទួលខុសត្រូវ សកម្មភាព ការពិភាក្សាគ្នា ការសហការ និងភាពផ្សេងៗគ្នាត្រូវបានរួមបញ្ចូលគ្នា ប្រសិទ្ធភាពនៃការសិក្សានិងមានការកើនឡើងយ៉ាងច្រើន។ នៅពេលការសិក្សាសកម្មនិងជំនាញនៃការត្រិះរិះពិចារណាត្រូវបានប្រើប្រាស់ សិស្សនិងរៀនកាន់តែច្រើន គិតកាន់តែច្រើន ធ្វើការកាន់តែច្រើន និង ឆ្លើយតបកាន់តែច្រើនថែមទៀត ទៅបញ្ហាប្រវត្តិសាស្ត្រ សង្គម បុគ្គល និងពលរដ្ឋដែលមានឥទ្ធិពលទៅលើជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន៕